នស / រកម / ០៧៩៩ / ០៣

# ព្រះរាជក្រម

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៩ ដែលប្រកាស អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

T/Letter head11

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការជំរុញ និងការការពារវិនិយោគ

# ច្បាប់

# ស្ដីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការជំរុញ និងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ស្ដីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅភ្នំពេញ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៦ ហើយដែលមានអត្ថបទ ទាំងស្រុងភ្ជាប់មកជាមួយ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្ទុកលើនីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋ ស្ដីទី

ហត្ថលេខា

ជា ស៊ីម

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ: ០៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

១៥១ [illegible]

# កិច្ចព្រមព្រៀង

# រវាង

# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

# ស្តីអំពី

# ការជំរុញ និង ការការពារវិនិយោគ

# កិច្ចព្រមព្រៀង

# រវាង

# រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

# ស្តីអំពី

# ការជំរុញ និង ការការពារវិនិយោគ

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន (ចាប់ពីពេលនេះតទៅត្រូវបានគេហៅថា « ភាគីកិច្ចសន្យា ») ។

ដោយមានគោលបំណងបង្កើតឡើង និង ថែរក្សានូវលក្ខណៈអនុគ្រោះសំរាប់ដំណើរការវិនិយោគដែលធ្វើឡើងដោយវិនិយោគិនទាំងឡាយនៃភាគីកិច្ចសន្យាមួយ នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ។

**ដោយទទួលស្គាល់ថា** ការលើកទឹកចិត្ត ការជំរុញ និង ការការពារវិនិយោគ [illegible] និងនាំទៅដល់ការផ្លាស់ប្តូរនៃគំនិតផ្តួចផ្តើមផ្នែកពាណិជ្ជកម្មរបស់ពួកអ្នកវិនិយោគទាំងឡាយ និង លើកកម្ពស់វិបុលភាពនៅក្នុងរដ្ឋទាំងពីរ ។

ដោយមានគោលបំណងពង្រីកសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ ដោយឈរលើមូលដ្ឋានស្មើភាព និង មានផលប្រយោជន៍ទៅវិញទៅមក ។

ភាគីកិច្ចសន្យាទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ –

# មាត្រា១÷

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ÷

១. ពាក្យ «វិនិយោគ» គឺសំដៅទៅលើរាល់ប្រភេទទ្រព្យសម្បត្តិដែលត្រូវបានដាក់ជាវិនិយោគដោយអ្នកវិនិយោគនៃភាគីកិច្ចសន្យាមួយ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិនានានៃភាគីកិច្ចសន្យាមួយទៀត នៅក្នុងទឹកដីរបស់ភាគីកិច្ចសន្យាមួយទៀតហើយជាពិសេសគឺត្រូវរាប់បញ្ចូលតែមិនកំរិតនូវទ្រព្យសម្បត្តិដូចខាងក្រោមនេះ ÷

ក. ចលនៈទ្រព្យ និង អចលនៈទ្រព្យ ព្រមទាំងសិទ្ធិផ្នែកកម្មសិទ្ធិដទៃៗទៀតមានដូចជាការបញ្ចាំ ការសន្យាផ្សេងៗ

ខ. ភាគហ៊ុន សន្និធិ ហើយនិងប្រភេទភាគហ៊ុនណាមួយផ្សេងទៀតនៅក្នុងក្រុមហ៊ុន

គ. ការទារប្រាក់ ឬ ប្រតិបត្តិការណាមួយផ្សេងទៀតដែលមានតម្លៃសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ឃ. កម្មសិទ្ធិបញ្ញា ទ្រព្យសម្បត្តិផ្នែកឧស្សាហកម្ម ចំណេះធ្វើ ដំណើរការបច្ចេកវិទ្យា សញ្ញាពាណិជ្ជកម្ម ហើយនិង ឈ្មោះពាណិជ្ជកម្ម

ង. សម្បទានដែលផ្តល់ដោយច្បាប់ ហើយរាប់បញ្ចូលទាំងសម្បទាននៅក្នុងការស្រាវជ្រាវរុករក ឬ ការធ្វើអាជីវកម្មប្រភពធនធានធម្មជាតិ ។

២. ពាក្យ «អ្នកវិនិយោគ» មានន័យថា ÷

សំរាប់ព្រះរាជាណាចក្រកម្ពុជា

ក. រូបវន្តបុគ្គលទាំងឡាយណាដែលមានសញ្ជាតិខ្មែរដោយអនុលោមទៅនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា

ខ. អង្គភាពសេដ្ឋកិច្ចទាំងឡាយណាដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង ដែលមានទីតាំងនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

សំរាប់សាធារណរដ្ឋប្រជាមានិតចិន

ក. រូបវន្តបុគ្គលទាំងឡាយណាដែលមានសញ្ជាតិចិន ដោយអនុលោមទៅនឹងច្បាប់របស់សាធារណរដ្ឋប្រជាមានិតចិន

ខ. អង្គភាពសេដ្ឋកិច្ចទាំងឡាយណាដែលបានបង្កើតឡើងដោយអនុលោមទៅតាមច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិន និង ដែលមានទីតាំងនៅក្នុងទឹកដីនៃសាធារណរដ្ឋប្រជាមានិតចិន ។

៣. ពាក្យថា «ប្រាក់ចំណូល» គឺសំដៅទៅដល់ចំនួនទឹកលុយដែលបានមកពីកិច្ចការវិនិយោគ ដូចជាប្រាក់ចំនេញ ប្រាក់ចំណេញតាមហ៊ុន ការប្រាក់ ប្រាក់ថ្លៃឈ្នួលហើយនិងចំណូលណាមួយផ្សេងទៀត ។

៤. ពាក្យថា«ទឹកដី» គឺសំដៅទៅដល់ទឹកដីនៃភាគីកិច្ចសន្យាមួយដូចដែលត្រូវបានកំណត់នៅក្នុងច្បាប់របស់ភាគីនោះ ព្រមទាំងតំបន់ភ្ជាប់ដែលភាគីនោះមានអធិបតេយ្យភាព សិទ្ធិអធិបតេយ្យភាព ឬ ដែលមានយុត្តាធិការដោយអនុលោមទៅនឹងច្បាប់អន្តរជាតិ ។

## មាត្រា ២ ÷

១. ភាគីកិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្តដល់ពួកអ្នកវិនិយោគរបស់ភាគីកិច្ចសន្យាមួយទៀត ដើម្បីធ្វើប្រតិបត្តិការ វិនិយោគនៅក្នុងទឹកដីរបស់ខ្លួន និងដើម្បីអនុញ្ញាត ទទួលនូវសកម្មភាពវិនិយោគទាំងនេះដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិនានារបស់ខ្លួន ។

២. ភាគីកិច្ចសន្យានីមួយៗត្រូវផ្តល់នូវការជួយព្រមទាំងសំរួលដល់ការផ្តល់ទិដ្ឋាការ ប័ណ្ណការងារចំពោះជនជាតិ នៃភាគីកិច្ចសន្យាមួយទៀតនៅក្នុងទឹកដីរបស់ខ្លួន ចំពោះសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ច ការវិនិយោគបែបនេះដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិរបស់ខ្លួន ។

## មាត្រា ៣÷

១. កិច្ចការវិនិយោគនិងសកម្មភាពទាំងឡាយ ដែលទាក់ទិននៅក្នុងដំណើរការវិនិយោគរបស់ពួកអ្នកវិនិយោគនៃភាគីកិច្ចសន្យានីមួយៗនឹងត្រូវបានផ្តល់នូវប្រព្រឹត្តិកិច្ចដោយយុត្តិធម៌ និង សមធម៌ ព្រមទាំងទទួលបាននូវកិច្ចការពារនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ។

២. ប្រព្រឹត្តិកិច្ច និង ការការពារដែលត្រូវបានចែងនៅក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះនឹងមិនត្រូវមានលក្ខណៈអនុគ្រោះតិចជាងប្រព្រឹត្តិកិច្ចដែលត្រូវបានផ្តល់ចំពោះដំណើរការវិនិយោគ និង សកម្មភាពនានាដែលពាក់ព័ន្ធទៅនឹងវិនិយោគបែបនេះរបស់ពួកអ្នកវិនិយោគនៃរដ្ឋទីបីឡើយ ។

៣. ប្រព្រឹត្តិកិច្ច និង ការការពារដូចដែលបានពោលបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី ១ និង ទី ២ នៃមាត្រានេះនឹងមិនត្រូវរាប់បញ្ចូលនូវប្រព្រឹត្តិកិច្ច ដែលមានលក្ខណៈអនុគ្រោះជាងដែលផ្តល់ដោយភាគីកិច្ចសន្យាមួយទៀតចំពោះដំណើរការវិនិយោគរបស់ពួកអ្នកវិនិយោគនៃរដ្ឋទីបីណាមួយ ដោយផ្អែកលើប្រយោជន៍នៃសហភាពគយ តំបន់ពាណិជ្ជកម្មសេរី សហព័ន្ធសេដ្ឋកិច្ច កិច្ចព្រមព្រៀង ដើម្បីជៀសវាងការយកពន្ធពីរដង ឬ កិច្ចព្រមព្រៀងដែលសំរួលដល់ពាណិជ្ជកម្មតាមព្រំដែន ។

## មាត្រា ៤÷

១. ពុំមានភាគីកិច្ចសន្យាណាមួយនឹងត្រូវធ្វើការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ធ្វើជាតូបនីយកម្ម ឬ ប្រកាន់យកវិធានការដែលស្រដៀងគ្នានេះ (ចាប់ពីពេលនេះតទៅត្រូវបានគេហៅថា «ការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់») ចំពោះសកម្មភាពវិនិយោគរបស់ពួកអ្នកវិនិយោគនៃភាគីកិច្ចសន្យាមួយទៀតនៅក្នុងទឹកដីរបស់ ខ្លួន លើកលែងតែលក្ខខណ្ឌដូចខាងក្រោមនេះត្រូវបានបំពេញ÷

ក. ដើម្បីផលប្រយោជន៍សាធារណៈ

ខ. ក្នុងលក្ខខណ្ឌនៃនីតិវិធីក្នុងស្រុក

គ. ដោយគ្មានការរើសអើង

ឃ. ដោយមានការទូទាត់សង

២. ការទូទាត់សងដូចដែលបានពោលបញ្ជាក់នៅក្នុង កថាខណ្ឌទី ១, (ឃ) នៃមាត្រានេះនឹងមានតំលៃសមមូលទៅនឹងតំលៃនៃវិនិយោគដែលត្រូវបានដកហូតតាមផ្លូវច្បាប់ នៅពេលដែលការដកហូតនេះត្រូវបានប្រកាស ហើយអាចធ្វើការផ្លាស់ប្តូរនិង ផ្ទេរដោយសេរី ។ ការទូទាត់សងនេះនឹងត្រូវធ្វើឡើងដោយពុំមានការពន្យាពេលដែលមិនសមហេតុផលឡើយ ។

## មាត្រា ៥÷

ពួកអ្នកវិនិយោគនៃភាគីកិច្ចសន្យាមួយទៀតដែលត្រូវទទួលការខាតបង់ដោយសារតែសង្គ្រាម ភាពអាសន្ន [illegible] ក្នុងប្រទេស ការបះបោរ កុប្បកម្ម ឬ ព្រឹត្តិការណ៍ដទៃទៀតដែលស្រដៀងគ្នានេះនឹងត្រូវបានទទួលពីភាគីកិច្ចសន្យាដែលជាម្ចាស់ទឹកដី ប្រសិនបើភាគីនេះធ្វើបានការសម្រួលនូវប្រព្រឹត្តិកិច្ចអនុគ្រោះ ដែលមិនតិចជាង ប្រព្រឹត្តិកិច្ចដែលពួកអ្នកវិនិយោគនៃរដ្ឋទីពាបានទទួលឡើយ ។

## មាត្រា ៦÷

១. ភាគីកិច្ចសន្យានីមួយៗ [illegible] តាមច្បាប់ និង បទបញ្ញត្តិរបស់ខ្លួននឹងត្រូវធានាដល់ពួកអ្នក វិនិយោគរបស់ភាគីកិច្ចសន្យាមួយទៀតចំពោះការផ្ទេរវិនិយោគ និង ប្រាក់ចំណូលរបស់ពួកគេ [illegible] ប្រព្រឹត្តទៅនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយដោយរាប់បញ្ចូលនូវ÷

ក. ប្រាក់ចំណេញ ប្រាក់ភាគលាភតាមហ៊ុន ការប្រាក់ ហើយនិងចំណូលស្របច្បាប់ដទៃទៀត

ខ. ចំនួនទឹកប្រាក់ដែលបានមកពីការរំលាយវិនិយោគទាំងមូល ឬ តាមផ្នែក

គ. ការសងសងដែលធ្វើឡើងតាមកិច្ចព្រមព្រៀងខ្ចីលុយដែលមានទំនាក់ទំនងនៅនឹង វិនិ[illegible]

៣. សាលាជំរះក្តីនេះមានអាជ្ញាកណ្តាល ៣រូប ។ នៅក្នុងរយៈពេល ២ ខែ ដោយគិតចាប់ពីថ្ងៃដែលភាគីកិច្ចសន្យានីមួយៗ បានទទួលនូវសេចក្តីប្រកាសជាលាយល័ក្ខអក្សរដែលស្នើឡើងអំពីការកាត់ក្តីតាមរយៈអាជ្ញាកណ្តាលពីភាគីកិច្ចសន្យាម្ខាង ភាគីកិច្ចសន្យានីមួយៗនឹងត្រូវធ្វើការតែងតាំងអាជ្ញាកណ្តាល ១ រូប ។ ក្នុងរយៈពេលពីរខែបន្ទាប់មកទៀត អាជ្ញាកណ្តាលទាំងពីររូបដោយរួមគ្នាតាមសេចក្តីយល់ព្រមនៃភាគីកិច្ចសន្យាទាំងពីរ ត្រូវជ្រើសរើសអាជ្ញាកណ្តាលទី៣ ដែលជាជនជាតិនៃរដ្ឋទី៣ ដែលមានទំនាក់ទំនងការទូតជាមួយភាគីកិច្ចសន្យាទាំងពីរ ។ អាជ្ញាកណ្តាលទី៣នេះនឹងត្រូវបានតែងតាំងដោយភាគីកិច្ចសន្យាទាំងពីរ ជាប្រធាននៃសាលាជំរះក្តីអាជ្ញាកណ្តាល ។

៤. ប្រសិនបើសាលាជំរះក្តីអាជ្ញាកណ្តាលមិនត្រូវបានរៀបចំបង្កើតឡើងទេ នៅក្នុងរយៈពេលបួនខែដោយគិតចាប់ពីថ្ងៃ នៃការទទួលលិខិតជាផ្លូវការស្នើរបស់ការកាត់សេចក្តីតាមរយៈអាជ្ញាកណ្តាល និងប្រសិនបើគ្មាននូវកិច្ចព្រមព្រៀងណាផ្សេងពីនេះទេ ភាគីកិច្ចសន្យានីមួយៗអាចធ្វើការអញ្ជើញប្រធាននៃតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីធ្វើការតែងតាំងជាអាជ្ញាកណ្តាល (១រូប ឬ ច្រើនរូប) ដែលមិនទាន់បានទទួលការតែងតាំងនៅឡើយ ។ ប្រសិនបើប្រធាននោះមានសញ្ជាតិដូចគ្នានៅនឹងភាគីកិច្ចសន្យាណាមួយ ឬត្រូវទទួលការ ហាមឃាត់មិនអោយបំពេញមុខនាទីដូចដែលបានពោលខាងលើ នោះសមាជិកជាន់ខ្ពស់នៃតុលាការយុត្តិធម៌អន្តរជាតិ ដែលពុំមានសញ្ជាតិដូចគ្នានៅនឹងភាគីកិច្ចសន្យាណាមួយនឹងត្រូវបានអញ្ជើញអោយទទួលការតែងតាំងដ៏ចាំបាច់នេះ ។

៥. សាលាជំរះក្តីអាជ្ញាកណ្តាលត្រូវកំណត់នីតិវិធីផ្ទាល់ខ្លួន ។ សាលាជំរះក្តីត្រូវធ្វើសេចក្តីសំរេចដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងគោលការណ៍នៃច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ដោយភាគីកិច្ចសន្យាទាំងពីរ ។

៦. សាលាជំរះក្តីត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួនតាមរយៈសម្លេងឆ្នោតភាគច្រើន ។ សេចក្តីសំរេចនេះគឺជាសេចក្តីសំរេចផ្តាច់ព្រាត់ ហើយមានប្រសិទ្ធភាពលើភាគីកិច្ចសន្យាទាំងពីរ ។ សាលាជំរះក្តីអាជ្ញាកណ្តាលពិសេស នឹងត្រូវធ្វើការពន្យល់ពីមូលហេតុទាំងឡាយនៃសេចក្តីសំរេចរបស់ខ្លួន នៅពេលដែលមានសំណើរបស់ភាគីកិច្ចសន្យាណាមួយ ។

៧. ភាគីកិច្ចសន្យានីមួយៗត្រូវបានទទួលបន្ទុកលើការចំណាយនៃការតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួន និងវត្តមានរបស់ខ្លួននៅក្នុងបណ្តឹងអាជ្ញាកណ្តាល ។ ការចំណាយដែលពាក់ព័ន្ធទៅនឹងប្រធាន ហើយនិងសាលាជំរះក្តីនឹងត្រូវបានរ៉ាប់រងតាមចំណែកស្មើគ្នាដោយភាគីកិច្ចសន្យា ។

ឃ. ប្រាក់ថ្លៃឈ្នួល ក្នុងកថាខ័ណ្ឌទី១, (ឃ) នៃមាត្រា១

ង. ការចំណាយទៅលើជំនួយបច្ចេកទេស ឬ ថ្លៃឈ្នួលសេវាបច្ចេកទេស និង ថ្លៃឈ្នួលសំរាប់ការគ្រប់គ្រង និង ចាត់ការ

ច. ការចំណាយលើកិច្ចសន្យាដែលទាក់ទងទៅនឹងគំរោង

ឆ. ប្រាក់ចំណូលរបស់ជនជាតិនៃភាគីកិច្ចសន្យាម្ខាងដែលបំពេញការងារពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគនៅ ក្នុងទឹកដីនៃភាគីកិច្ចសន្យាម្ខាងទៀត ។

២. ការផ្ទេរដូចដែលបានពោលពីខាងលើនឹងត្រូវធ្វើឡើង តាមអត្រាប្តូរប្រាក់នៃទីផ្សារជាធម្មតានៃភាគីកិច្ចសន្យាដែលទទួលយកវិនិយោគនៅក្នុងថ្ងៃនៃការផ្ទេរ ។

## មាត្រា ៧៖

ប្រសិនបើភាគីកិច្ចសន្យាណាមួយ ឬ ក៏ទីភ្នាក់ងារណាមួយដែលបង្កើតឡើងដោយភាគីកិច្ចសន្យានោះធ្វើការទូទាត់សងចំពោះអ្នកវិនិយោគណាម្នាក់តាមលក្ខខ័ណ្ឌនៃការធានារ៉ាប់រងដែលភាគីនោះបានផ្តល់ ដោយសំដៅទៅលើវិនិយោគណាមួយរបស់អ្នកវិនិយោគនោះនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ភាគីកិច្ចសន្យានោះត្រូវទទួលស្គាល់ការផ្ទេរសិទ្ធិ ឬ បណ្តឹងរបស់ អ្នកវិនិយោគបែបនេះទៅអោយភាគីកិច្ចសន្យាម្ខាងទៀត ឬ ភ្នាក់ងាររបស់ភាគីនោះហើយត្រូវទទួលស្គាល់ការទទួលសិទ្ធិជំនួសរបស់ភាគីកិច្ចសន្យានោះ ឬ ភ្នាក់ងាររបស់ភាគីនោះនៅលើសិទ្ធិ និង បណ្តឹងបែបនេះ ។ សិទ្ធិផ្ទេរបន្ត ឬ បណ្តឹងមិនត្រូវអោយគេលើសពីសិទ្ធិ ឬ បណ្តឹងខាងដើមរបស់អ្នកវិនិយោគដូចដែលបានពោលមកហើយនោះទេ ។

## មាត្រា ៨៖

១. វិវាទណាមួយក៏ដោយដែលកើតមានរវាងភាគីកិច្ចសន្យាដោយពាក់ព័ន្ធទៅនឹងបំណកស្រាយ ឬ ការអនុវត្តកិច្ចព្រមព្រៀងនេះនឹងត្រូវដោះស្រាយអោយអស់លទ្ធភាព ដោយការពិគ្រោះតាមរយៈបណ្តាញការទូត ។

២. ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបានតាមរបៀបនេះនៅក្នុងរយៈពេល ៦ ខែ ដោយអាស្រ័យទៅលើសំណើររបស់ភាគីកិច្ចសន្យាធិមួយៗ វិវាទនោះនឹងត្រូវបានដាក់អោយសាលាជំរះក្តីអាជ្ញាកណ្តាលពិសេសធ្វើការពិនិត្យ និង សំរេច ។

## មាត្រា ៩ ៖

១. វិវាទណាក៏ដោយដែលកើតឡើងរវាងអ្នកវិនិយោគនៃភាគីកិច្ចសន្យាមួយ ហើយនិងភាគីកិច្ចសន្យាមួយទៀតនៅក្នុងទំនាក់ទំនងនៃកិច្ចការវិនិយោគក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយ នឹងត្រូវដោះស្រាយក្នុងគ្រប់លទ្ធភាព និង ដោយមេត្រីភាពតាមរយៈការចរចារវាងភាគីនៅក្នុងវិវាទ ។

២. ប្រសិនបើវិវាទនោះមិនអាចត្រូវបានដោះស្រាយតាមរយៈការចរចានៅក្នុងរយៈពេល ៦ ខែ ភាគីនីមួយៗ នៅក្នុងវិវាទនឹងត្រូវបានប្រគល់នូវសិទ្ធិអំណាចដើម្បីដាក់វិវាទនោះអោយតុលាការមានសមត្ថកិច្ចរបស់ភាគីកិច្ចសន្យាដែលទទួលប្រតិបត្តិការវិនិយោគពិនិត្យ និង សំរេច ។

៣. ប្រសិនបើវិវាទណាមួយ ពាក់ព័ន្ធទៅនឹងចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងចំពោះការដកហូតទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ពុំអាចត្រូវបានដោះស្រាយក្នុងរយៈពេល ៦ខែ បន្ទាប់ពីមធ្យោបាយចរចាដូចបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី ១នៃមាត្រានេះ វិវាទនោះអាចត្រូវបានដាក់អោយសាលាជំរះក្តីអាជ្ញាកណ្តាលពិសេសពិនិត្យសំរេចតាមការស្នើរបស់ភាគីណាមួយ ។ លក្ខខ័ណ្ឌទាំងឡាយនៃកថាខ័ណ្ឌនេះ នឹងមិនត្រូវបានអនុវត្តទេ ប្រសិនបើអ្នកវិនិយោគដែលពាក់ព័ន្ធបានប្រកាន់យកនីតិវិធីដូចដែលបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី២នៃមាត្រានេះ ។

៤. សាលាជំរះក្តីអាជ្ញាកណ្តាលពិសេសនេះ នឹងត្រូវបានរៀបចំឡើងតាមករណីនីមួយៗតាមវិធីដូចតទៅនេះ ៖ ភាគីនីមួយៗនៅក្នុងវិវាទនេះត្រូវតែតែងតាំងអាជ្ញាកណ្តាលម្នាក់ ហើយអាជ្ញាកណ្តាលទាំងពីរនេះនឹងត្រូវជ្រើសរើសជនជាតិនៃប្រទេសទីបី ដែលមានទំនាក់ទំនងការទូតជាមួយនឹងភាគីកិច្ចសន្យាទាំងពីរអោយធ្វើជាប្រធាន ។ អាជ្ញាកណ្តាលទាំងពីររូប ដំបូងត្រូវបានតែងតាំងឡើងនៅក្នុងអំឡុងពេលពីរខែ នៃការចេញសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដើម្បីរៀបចំការកាត់សេចក្តីតាមប្រព័ន្ធអាជ្ញាកណ្តាល ដែលធ្វើឡើងដោយភាគីនីមួយៗនៅក្នុងវិវាទ ហើយប្រធាននោះត្រូវបានគេជ្រើសរើសនៅក្នុងរយៈពេល ៤ខែ ។ ប្រសិនបើនៅក្នុងរយៈពេលដូចដែលបានបញ្ជាក់ខាងលើសាលាជំរះក្តីពុំត្រូវបានគេរៀបចំបង្កើតឡើងទេ ភាគីនីមួយៗនៅក្នុងវិវាទអាចអញ្ជើញអគ្គលេខាធិការនៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដំណោះស្រាយវិវាទវិនិយោគតែងតាំងដែលចាំបាច់ ។

៥. សាលាជំរះក្តីត្រូវកំណត់នីតិវិធីផ្ទាល់ខ្លួន ។ តែទោះបីជាយ៉ាងណា នៅក្នុងការកំណត់នីតិវិធីនោះ សាលាជំរះក្តីអាចយកការណែនាំពីគោលការណ៍អាជ្ញាកណ្តាលនៃមជ្ឈមណ្ឌលអន្តរជាតិ សំរាប់ដំណោះស្រាយវិវាទវិនិយោគ ។

៦. សាលាជំរះក្តីត្រូវធ្វើសេចក្តីសំរេចតាមសន្លឹកឆ្នោតភាគច្រើន ។ សេចក្តីសំរេចនេះគឺជាសេចក្តីសំរេចផ្តាច់ព្រាត់ហើយមានប្រសិទ្ធភាពលើភាគីកិច្ចសន្យាទាំងពីរ ។ ភាគីកិច្ចសន្យាទាំងពីរត្រូវប្តេជ្ញាអនុវត្តសេចក្តីសំរេចនេះ ដែលអនុលោមទៅតាមច្បាប់ក្នុងស្រុកនៃប្រទេសរៀងៗខ្លួន ។

៧. សាលាជំរះក្តីត្រូវវិនិច្ឆ័យ ដោយអនុលោមទៅតាមច្បាប់របស់ភាគីកិច្ចសន្យាក្នុងវិវាទដែលធ្វើវិនិយោគ ដោយរាប់បញ្ចូលនូវបទបញ្ញត្តិលើវិវាទលើច្បាប់ លក្ខខ័ណ្ឌនានានៃកិច្ចព្រមព្រៀង ហើយនិង គោលការណ៍ដែលត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុងច្បាប់អន្តរជាតិ ដែលទទួលយកដោយភាគីកិច្ចសន្យាទាំងពីរ ។

៨. ភាគីកិច្ចសន្យានីមួយៗត្រូវបានទទួលរ៉ាប់រងសោហ៊ុយតម្លៃនៃការតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួន និងវត្តមានរបស់ខ្លួននៅក្នុងបណ្តឹងអាជ្ញាកណ្តាល ។ សោហ៊ុយដែលពាក់ព័ន្ធទៅនឹងប្រធាន ហើយនិងសាលាជំរះក្តីនឹងត្រូវបានរ៉ាប់រងតាមចំណែកស្មើៗគ្នាដោយភាគីកិច្ចសន្យា ។

## មាត្រា ១០÷

កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តចំពោះដំណើរការវិនិយោគដែលធ្វើឡើងនៅមុនពេល ឬ ក្រោយពេលនៃការចូលជាធរមាន ដោយពួកអ្នកវិនិយោគនៃភាគីកិច្ចសន្យានីមួយៗ ហើយត្រូវអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិនានារបស់ភាគីកិច្ចសន្យាមួយទៀតនៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ១១÷

១. អ្នកតំណាងនៃភាគីកិច្ចសន្យាទាំងពីរត្រូវចាត់តាំងអង្គប្រជុំជាម្តងម្កាលដើម្បី៖

ក. ពិនិត្យឡើងវិញនូវការអនុវត្តកិច្ចព្រមព្រៀង

ខ. ផ្លាស់ប្តូរពត៌មានតាមផ្លូវច្បាប់ និង ឱកាសនានាខាងផ្នែកវិនិយោគ

គ. ដោះស្រាយពំណោះដែលកើតចេញពីសកម្មភាពវិនិយោគ

ឃ. លើកសំណើសំរាប់ការពង្រីកពង្រឹងវិនិយោគ

ង. សិក្សាពីបញ្ហានានាដែលពាក់ព័ន្ធក្នុងកិច្ចការវិនិយោគ

២. ក្នុងករណីដែលភាគីកិច្ចសន្យានីមួយៗ ដាក់សំណើរចំពោះការពិគ្រោះអំពីកិច្ចការនៃចំនុចណាមួយនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះភាគីកិច្ចសន្យាមួយទៀតត្រូវផ្តល់ការឆ្លើយតបជាបន្ទាន់ ហើយការពិគ្រោះនឹងត្រូវបានធ្វើឡើង តាមធម្មតានៅក្រុងប៉េកាំង និង ភ្នំពេញ ។

## មាត្រា ១២៖

១. កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងថ្ងៃទី១នៃខែបន្ទាប់ នៅក្រោយពេលដែលភាគីកិច្ចសន្យាទាំងពីរបានផ្តល់នូវសេចក្តីប្រកាសជាលាយល័ក្ខអក្សរបស់គ្នាទៅវិញទៅមក ដោយបញ្ជាក់ថានីតិវិធីផ្ទៃក្នុងរៀងៗខ្លួនរបស់ពួកគេត្រូវបានបំពេញហើយ ។កិច្ចព្រមព្រៀងនេះនឹងត្រូវស្ថិតជាធរមានក្នុងរយៈពេល ៥ឆ្នាំ ។

២. កិច្ចព្រមព្រៀងនេះនឹងត្រូវបន្តប្រសិទ្ធភាព ប្រសិនបើភាគីកិច្ចសន្យានីមួយៗពុំបានផ្តល់នូវលិខិតប្រកាសជាផ្លូវការដល់ភាគីម្ខាង ដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះក្នុងរយៈពេលមួយឆ្នាំមុនការផុតកំណត់ដូចដែលបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌទី១នៃមាត្រានេះ ។

៣. នៅក្រោយការផុតកំណត់នៃរយៈពេល ៥ឆ្នាំដំបូង ភាគីកិច្ចសន្យានីមួយៗអាចបញ្ចប់កិច្ចព្រមព្រៀងនេះ នៅពេលណាមួយក៏បាន ដោយការផ្តល់លិខិតជាផ្លូវការក្នុងរយៈពេលមួយឆ្នាំយ៉ាងតិចដល់ភាគីកិច្ចសន្យាមួយទៀត ។

៤. ដោយគោរពទៅតាមលក្ខខ័ណ្ឌវិនិយោគដែលត្រូវបានបង្កើតឡើងនៅមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ ខនាទៅនៃមាត្រា ១ ដល់មាត្រា ១២ នឹងត្រូវបន្តប្រសិទ្ធិភាពនៅក្នុងរយៈពេល ១០ឆ្នាំថែមទៀតដោយគិតចាប់ពីថ្ងៃនៃការបញ្ចប់ ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកចុះហត្ថលេខាខាងក្រោម ត្រូវបានផ្តល់នូវសិទ្ធិអំណាចយ៉ាងត្រឹមត្រូវ ដោយរដ្ឋាភិបាលរៀងៗខ្លួន និង បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ឯកសារនេះត្រូវបានចំលងចេញជាពីរច្បាប់ដូចគ្នាបេះបិទនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ១៩៩៦ ជាភាសាខ្មែរ ចិន និង ភាសាអង់គ្លេស ដោយរាល់អត្ថបទក៏ត្រូវមានលក្ខណៈស្របច្បាប់ដូចគ្នា ។ ករណីនៃភាពខុសប្លែកគ្នាក្នុងបំណកស្រាយ អត្ថបទជាភាសាអង់គ្លេសនឹងត្រូវសំរេចយកជាផ្លូវការ ។

តំណាងអោយរដ្ឋាភិបាលនៃ
ព្រះរាជាណាចក្រកម្ពុជា

តំណាងអោយរដ្ឋាភិបាលនៃ
សាធារណរដ្ឋប្រជាមានិតចិន